**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :......៧១៦/២០......**ក.ប**/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឱ្យប្រើនិមិត្តសញ្ញាសម្គាល់ របស់បេឡាជាតិសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមការចាំបាច់របស់បេឡាជាតិសន្តិសុខសង្គម



*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩*

## សម្រេច

### ប្រការ ១.-

ត្រូវបានអនុញ្ញាតឱ្យប្រើនិមិត្តសញ្ញាសម្គាល់ របស់បេឡាជាតិសន្តិសុខសង្គម។ និមិត្តសញ្ញាសម្គាល់នេះមានគំរូដូចខាងក្រោម៖

### ប្រការ ២.-

និមិត្តសញ្ញាសម្គាល់នេះមានខ្លឹមសារ និងអត្ថន័យដូចខាងក្រោម៖

- មានរាងទាំងមូល រាងមូល ព័ទ្ធដោយកួរស្រូវរាងស្នែងក្របីពណ៌ទឹកមាស រូបរាងខាងក្នុងមាន រូបមនុស្សប្រុស-ស្រី នៅខាងក្នុងកងចក្រ និងគម្របពណ៌ទឹកសមុទ្ររាងជាពាក់កណ្តាលរង្វង់។ នៅលើផ្ទៃគម្របកងចក្រមានសរសេរអក្សរ "ប.ស.ស." និង "NSSF" ។ ព័ទ្ធជុំវិញកងចក្រមានផ្ចុំតួអក្សររាងជារង្វង់ដាក់ថា " បេឡាជាតិសន្តិសុខសង្គម " និង "National Social Security Fund"
- កួរស្រូវពណ៌ទឹកមាសមាន ៩ថ្នាក់ តំណាងនូវតារកាលិកទាំងប្រាំបួន ដែលចែងក្នុងបទដ្ឋានអន្តរជាតិស្តីពីសន្តិសុខសង្គម
- អក្សរ បេឡាជាតិសន្តិសុខសង្គម និង National Social Security Fund ពណ៌ទឹកសមុទ្ររាងជារង្វង់ តំណាងឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានបេសកកម្មក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមសម្រាប់បុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ
- រូបពាក់កណ្តាលរង្វង់គ្របពីលើកងចក្រ ពណ៌ទឹកសមុទ្រ ដែលមានអក្សរ ប.ស.ស. និង NSSF ពណ៌ស តំណាងនូវការការពារហានិភ័យសង្គម ចំពោះបុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

- រូបកងចក្ររាងពាក់កណ្តាលរង្វង់ពណ៌ទឹកសមុទ្រ តំណាងនូវការចូលរួមនៃវិស័យសាធារណៈ និងវិស័យឯកជន។ រីឯកាំកងចក្រចំនួន ១១ តំណាងនូវសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គមទាំង១១រូប
- រូបមនុស្សប្រុស-ស្រីស្ថិតនៅខាងក្នុងកងចក្រតំណាងនូវបុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលត្រូវទទួលបានការការពារពីរបបសន្តិសុខសង្គមតាមច្បាប់។

**ប្រការ ៣.-**

សញ្ញារបស់បេឡាជាតិសន្តិសុខសង្គម ត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម ៖

- ប្រើប្រាស់លើក្បាលលិខិតជាផ្លូវការរបស់អង្គភាព
- ដាក់នៅកន្លែងធ្វើការ
- ពាក់នៅលើឯកសណ្ឋានមន្ត្រីរាជការរបស់អង្គភាព
- ប្រើប្រាស់ជាផ្លូវការផ្សេងៗ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម គ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១១កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ